ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៙៛

តុលាការកំពូល

ស្រស

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣៨

ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៨

សាលដីកា

លេខ : ២២១

ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១_ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២_លោក ប៉ែន ស៊ិន ជាចៅក្រម

៣_លោក វៀល មួន ចៅក្រម

៤_លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៥_លោក ជីវ កេង ចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៧៥៨ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥៨១ ចុះថ្ងៃទី ២៣.៩.៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ វ៉ាន់ ថៃសាន ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ របររកស៊ី យោធា ទីលំនៅសព្វថ្ងៃ ភូមិចំការ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ វ៉ាន់ "ស" ម្តាយឈ្មោះ ទួត វ៉ែម ។ ទទួលសិទ្ធិជំនួសម្តាយ ។

និង ចុងបណ្តឹងសាទុក្ខឈ្មោះ មិត្ត ហួត ភេទស្រី អាយុ ៤៧ឆ្នាំ ជាតិខ្មែរ របររកស៊ី ធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិចំការស្វាយ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ ឌិត មិត្ត "រ" ម្តាយឈ្មោះ ឃុត ប៊ុន "ស" ។

កម្មវត្ថុបណ្តឹង : ប្តឹងសុំសិទ្ធិគ្រប់គ្រងដីភូមិ

តាមបណ្តឹងសាទុក្ខលេខ ៤៨២ ចុះថ្ងៃទី ១៦.១២.៩៧ របស់ឈ្មោះ វ៉ាន់ ថៃសាន ទទួលសិទ្ធិពីអ្នកស្រី ទួត វ៉ែម ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ៧៥៨ ចុះថ្ងៃទី ១៥.១២.៩៧ របស់សាលាឧទ្ធរណ៍ លើចំនុច នៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៦.៣.៩៥ របស់ឈ្មោះ មិត្ត ហួត ប្តឹងទារដីពីឈ្មោះ វ៉ាន់ ហោ ដោយសំអាងហេតុថា ដីនោះខ្លួន រស់នៅនឹងគ្រប់គ្រង តាំងពីឆ្នាំ ១៩៧៩ ។

លុះថ្ងៃទី ២៥.១២.៨៤ ឈ្មោះ វ៉ាន់ ហោ មកដាំក្រូចលើដីរបស់ខ្លួន និង ថ្ងៃទី០៥.៣.៨៥ ឈ្មោះនេះបានអោយកូនដាំចេកពាសពេញដីរបស់ខ្លួន ។

បានឃើញសាលក្រមលេខ ១២២ ចុះថ្ងៃទី ១៦.៥.៨៦ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ក.ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០៦.៣.៨៥ របស់ឈ្មោះនាង មិត្ត ហួត សុំសិទ្ធិគ្រប់គ្រងដីពីឈ្មោះ វ៉ាន់ ហោ "ស្លាប់" និង ប្រពន្ធឈ្មោះ ទួត រ៉េម ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

ខ.ទទួលយកសំរួមពារ របស់ឈ្មោះនាង មិត្ត ហួត ជាដើមចោទ សុំសិទ្ធិគ្រប់គ្រងប្រើប្រាស់ដីទំនាស់ សំរាប់រស់នៅតទៅ និង សុំទាមទារដំណាំទាំងអស់នៅលើដីទំនាស់ធ្វើជាកម្មសិទ្ធិរបស់ខ្លួន ទុកជាត្រឹមត្រូវតាមច្បាប់ ។

គ.បដិសេធចោលសំរួមពាររបស់តំណាងស្របច្បាប់ នៃចុងចម្លើយ សុំសិទ្ធិគ្រប់គ្រងដីទំនាស់ និង សុំអោយដើមចោទរស់នៅលើដីតែមួយបាតផ្ទះ ដោយខ្លួនសុំទាមទារ ថ្លៃដីចំនួន ១.០០០.០០០៛ ដោយខុសនឹងគតិច្បាប់ ។

២-ប្រគល់ដីទំនាស់ និង ដំណាំទាំងអស់នៅលើដីទំនាស់ អោយឈ្មោះនាង មិត្ត ហួត ជាដើមចោទ អាស្រ័យនៅ ប្រើប្រាស់ និង អាស្រ័យផល ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ដែលមានទំហំ ៧០២,៥២ម² មានព្រំប្រទល់ខាងជើងទល់ស្ទឹងប្រវែង១៨,៣០ម ខាងត្បូងទល់ផ្លូវ ប្រវែង ១៣,០០ម ខាងកើតទល់ឈ្មោះ អួច គន ប្រវែង៤៦,០០ម និង ខាងលិចទល់ឈ្មោះ ព្រំ វ៉ន ប្រវែង ៤១,០០ម ស្ថិតនៅភូមិចំការស្វាយ ឃុំឈើទាល ស្រុកបាណន់ ខេត្ត បាត់ដំបង ។

៣-អោយឈ្មោះនាង មិត្ត ហួត ជាដើមចោទចេញថ្លៃដំណាំ នៅលើដីទំនាស់ មានដំណាំចាស់ គឺ ដូង ចំនួន០៩ដើម ស្វាយ០១ដើម ល្មុត០១ដើម និង ដំណាំថ្មីមានចេកចំនួន ៧៦គុម្ព ដល់ឈ្មោះនាង ទួត រ៉េម ជាចុងចម្លើយ ជាប្រាក់រៀលចំនួន ២០០.០០០៛ "ពីររយពាន់រៀលគត់" ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

តាមអនុក្រឹត្យលេខ ២៥អនក្រ ចុះថ្ងៃទី ២២.៤.៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃ រដ្ឋកម្ពុជា ។

តាមមាត្រា ៥.២៨.៦២.៦៤.៦៥.៦៨.៧១ និង មាត្រា ៧២ នៃច្បាប់ភូមិបាល ដែលប្រកាសអោយប្រើ តាមក្រឹត្យលេខ ១០០ ក្រ ចុះថ្ងៃទី ១៣.១០.៩២ ។

៤-អោយចុងចម្លើយឈ្មោះនាង ទួត រ៉េម បង់ប្រាក់ប្រដាប់ក្តី គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ចំនួន ១.៨០០៛

-រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛

-រង្វាន់អ្នកប្រគល់ដីការកោះចំនួន ២.០០០៛

-ចំណាយលើកិច្ចស៊ើបសួរ ចំនួន ៣.០០០៛

បូកសរុបចំនួន ៧.០០០៛ ។ ប្រាក់នេះកាត់យកពីប្រាក់ ចំនួន ៧.០០០៛ ដែលដើមចោទ បានបង់រួចហើយ បើសាលក្រមនេះចូលជាស្ថាពរ អោយចុងចម្លើយសងទៅដើមចោទវិញ ។

និង អោយបង់ពន្ធសមាមាត្រជាប្រាក់រៀល ចំនួន ៧០២០៛ ។ ប្រាក់នេះដាក់ចូល ថវិការដ្ឋចំនួន ៨០ភាគរយ និង ដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន២០ ភាគរយ បើសាលក្រមនេះចូលជាស្ថាពរ ។

តាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ដែលប្រកាសអោយប្រើ តាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ០៨.០២.៩៣ ។

សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូភាគី ។

បើកផ្លូវឧទ្ធរណ៍កំណត់ ២ខែ គិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ វ៉ាន់ ថៃសាន ចុះថ្ងៃទី ១២.៦.៩៦ ប្ដឹងមិនសុខចិត្ត លើសេចក្ដីសំរេច នៃសាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៥៣១ ចុះថ្ងៃទី ០៩.៩.៩៧ ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១២.៦.៩៦ របស់ឈ្មោះ វ៉ាន់ ថៃសាន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោល ដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១២២ ចុះថ្ងៃទី ១៦.៥.៩៦ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣-សំរេចកាត់យកប្រាក់ប្រដាប់ក្ដី នៅជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០៛ ដែលដើមបណ្ដឹងឧទ្ធរណ៍ បានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង អាជ្ញាធរតុលាការ ៥០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និង កំបាំងមុខចុងចម្លើយ ។

-សំរេចបើកផ្លូវប្ដឹងទាស់ និង ប្ដឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់របស់ឈ្មោះ វ៉ាន់ ថៃសាន ចុះថ្ងៃទី ២៣.៩.៩៧ ប្ដឹងមិនសុខចិត្ត លើសេចក្ដីសំរេច នៃ សាលដីកាទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៧៥៨ ចុះថ្ងៃទី ១៥.១២.៩៧ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី ២៣.៩.៩៧ របស់ឈ្មោះ វ៉ាន់ ថៃសាន

ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោល ដោយទាស់ខុសនឹងគតិច្បាប់ ។

២_តម្កល់សាលដីកាកំប៉ាំងមុខលេខ ៥៣១ ចុះថ្ងៃទី ០៩.៩.៩៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣_សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី

_សំរេចបើកផ្លូវ ប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៨២ ចុះថ្ងៃទី ១៦.១២.៩៧ របស់ឈ្មោះ វ៉ាន់ថៃសាន ទទួលសិទ្ធិពីអ្នកស្រី ទូត រ៉េម ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី ២៦.៣.៩៨ របស់ឈ្មោះ វ៉ាន់ ថៃសាន ។

បានឃើញសារណាតបចុះថ្ងៃទី ០២.៧.៩៩ របស់ឈ្មោះ ឈួប សាវរឿត ទទួលសិទ្ធិពីឈ្មោះ មិត្ត ហួត ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :

_បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។ សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ និង គតិច្បាប់ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ វ៉ាន់ ថៃសាន ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

_ខ្លួនគ្រប់គ្រង និង អាស្រ័យផល លើដំណាំនេះ តាំងពីឆ្នាំ ១៩៧៩ ដែលមានក្បាល ១៣ម គុណ ៣០ម ហើយមានដើមខ្នុរ ចេក... ។ ឈ្មោះ មិត្ត ហួត មកសុំដីខ្លួនស្នាក់នៅ នៅក៏នៅចុះ តែផលដំណាំ ខ្លួនមិនអោយទេ គឺខ្លួនសុំគ្រប់គ្រង ។

បានស្តាប់ចម្លើយរបស់ឈ្មោះ មិត្ត ហួត ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

_ខ្លួនរស់នៅលើដីនេះ តាំងពីឆ្នាំ ១៩៧៩ រហូតមក មានមេភូមិ ឃុំ ទទួលស្គាល់ និង អោយនៅ ដែលមានក្បាល ១៤ម គុណ ៤៥ម និង មានដំណាំ ពីមុន ដំណាំទាំងនេះមិនមែនឈ្មោះ វ៉ាន់ ថៃសាន ជាអ្នកបេះទេ គឺ ភូមិ ឃុំ ជាអ្នកបេះ ដល់ឆ្នាំ ១៩៩៥ ឈ្មោះ វ៉ាន់ ថៃសាន យកចេកមកដាំ ហើយក៏បេះផលដំណាំទាំងនេះ ។ ខ្លួនសូមពរសុំអោយ តុលាការធ្វើតាមច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ ចម្លើយដោះសារ របស់គូភាគី

-ក្រោយពីបាន ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៨២ ចុះថ្ងៃទី ១៦.១២.៩៧ របស់លោក វ៉ាន់ វិចសាន ទទួលសិទ្ធិពីអ្នកស្រី ទូត រ៉េម ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការ ចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចតុលាការខេត្តបាត់ដំបងដែរ ដែលសំរេចប្រគល់ដីចំនាស់ទំហំ ៧០២,៥២ម$^{២}$ និងដំណាំទាំងអស់នៅលើដីចំនាស់ ស្ថិតនៅភូមិចំការស្វាយ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង អោយទៅអ្នកស្រី មិត្ត ហួត គឺជាការភ័ន្តច្រឡំ ពីព្រោះ ថា :

•ក្នុងពាក្យបណ្តឹង ក៏ដូចក្នុងកំណត់ហេតុផ្សះផ្សា សំរុះសំរួល អ្នកស្រី មិត្ត ហួត ប្តឹងទាមទារដីចំនាស់ តែទំហំ ២៥ម គុណ ១៥ម ហើយនៅពេលសវនាការ ក៏អ្នកស្រីមិត្ត ហួត ទាមទារតែទំហំ ៣០ម គុណ ១៣ម ដែលមានផ្ទៃក្រឡាមិនលើសពី ៣៩០ម$^{២}$ ឡើយ ។

•ក្នុងការយល់ឃើញរបស់ខ្លួន តុលាការខេត្តបាត់ដំបង ក៏បានទទួលស្គាល់ ផងដែរ ថា : ចុងចម្លើយអ្នកស្រី ទូត រ៉េម អាស្រ័យផលដំណាំចាស់តាំងពីឆ្នាំ ១៩៧៨ រហូតមក និង បានដាំដំណាំថ្មី ដោយពុំមានការហាមឃាត់ ពីដើមចោទ អ្នកស្រី មិត្ត ហួត ឡើយ ដូច្នេះចុងចម្លើយ អ្នកស្រី ទូត រ៉េម មានសិទ្ធិពេញបរិបូណ៌ ក្នុងការកាន់កាប់ដីចំនាស់ និង ដំណាំលើដីចំនាស់ ក្នុងចំណែកណាមួយ ដោយពិតប្រាកដ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៧៥៨ ចុះថ្ងៃទី ១៥.១២.៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៨២ ចុះថ្ងៃទី ១៦.១២.៩៧ របស់លោក វ៉ាន់វិចសាន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៧៥៨ ចុះថ្ងៃទី ១៥.១២.៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨ ចុះថ្ងៃទី ១៦.០២.៩៨ របស់តុលាការ

កំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន ១៩.០០០៛ ដែលអ្នកស្រី ខួត វើម បានបង់ទុកជាមុន គឺ :

-ពន្ធចុះបញ្ជីក្ដី និង ពន្ធឡឹងចំនួន ៤.០០០៛ ប៉ុន្ដែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយត្រូវអោយអ្នកស្រី មិត្ត ហួត សងប្រាក់ចំនួន ១៩.០០០៛ នេះទៅអោយអ្នកស្រី ខួត វើមវិញ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៩៩ ។